# បទ ពង្សាវតារខ្មែរ



១ ខ្មែរអើយចូរចាំជាក់ថា តាមពង្សាវតារ
បញ្ជាក់ប្រាប់ថា ពូជខ្មែរថ្កើង
ទឹកដីខ្មែរធំ ទូលំទូលាយ
សព្វសាយរុងរឿង គេឯងតែងលើកតំកើង
តំកល់ជាតិយើង ចាត់ទុកឡើងជាជាតិច្បង។
២ អារ្យធម៌ខ្ពង់ខ្ពស់ឆើតឆាយ បានចេញផ្សព្វផ្សាយ
គ្រប់ទិសទាំងឡាយ ចុងបូព៌ា
សាសនាសិល្បៈ ចំលាក់វិចិត្រ
គំនិតសិក្សា តន្ត្រីទស្សនវិជ្ជា
អាចយកសិក្សា ជាគោលការណ៍ ដែលខ្មែរផ្សាយទៅ។
៣ ខ្មែរអើយចូរស្តាប់សាវតារ ដែលបានចរចា
បញ្ជាក់ប្រាប់ថា ពូជខ្មែរថ្កើង
តាំងចិត្តអោយធំ ខិតខំប្រឹងវិញ
បញ្ចេញតំកើង តំលៃនៃជាតិខ្មែរយើង
ឲ្យបានរុងរឿង ជាថ្មីឡើងតាមសាវតារ ។

ព្រះរាជនិពន្ធ សម្តេចព្រះសង្ឃរាជ ជួន ណាត



វាយចម្លងដោយខ្ញុំបាទ អ៊ិន លី ថ្ងៃទី៤ ខែតុលា គ.ស ២០១៣

# សាវតារខ្មែរ

*ខ្មែរអើយ ចូរចាំជាក់ថា តាមសាវតា ជាតិខេមរា ធ្លាប់តែថ្កើង ទឹកដីខ្មែរធំ ទូលំទូលាយ

សុះសាយរុងរឿង គេឯង តែងលើកដំកើងដំកល់ជាតិយើង ចាត់ទុក ឡើងជាជាតិច្បង ។

*អារ្យធមិខ្មែរ ខ្ពង់ខ្ពស់ឆើតឆាយ បានចេញផ្សព្វផ្សាយគ្រប់ទិសទាំងឡាយ ចុងបូពា

សាសនាសិល្បៈ ចម្លាក់វិចិត្ត គំនិតសិក្សា តន្ត្រី ទស្សនវិជ្ជា យុទ្ធសាស្ត្រាជាគោលការណ៍ខ្មែរផ្សាយទៅ ។

*ខ្មែរយើង ចូរស្តាប់សាវតារ ដែលបានចរចា បញ្ជាក់ប្រាប់ថាពូជខ្មែរថ្កើង តាំងចិត្តឱ្យមាំ

ខិតខំប្រឹងវេញ បញ្ចេញដំកើង តម្លៃ នៃ ជាតិខ្មែរយើង ឱ្យបានរុងរឿង ជាថ្មីឡើង តាមសាវតារ ។

ចម្លងជូនដោយខ្ញុំបាទ **ទ៉ាន់ អ៊ុង**

ខ្ញុំឥតចេះច្រៀងទេ បើចម្លងជូនខុសឃ្លាឬខុសរបៀបបែបបទចំរៀង សូមលោកអ្នកដែលចេះជួយកែផង ។

វាយចម្លងដាក់គេហទំព័រវត្តសាវតារខ្មែរដោយខ្ញុំបាទ អ៊ិន លី ថ្ងៃទី៩ខែកុម្ភៈឆ្នាំ២០១២

